ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# សុន្ទរកថា

## ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ថ្លែងក្នុងឱកាសបិទ

## កិច្ចប្រជុំពេញអង្គនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២០

## ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០

**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បន្ទប់ប្រជុំ ខ និងតាមបណ្តាញវីដេអូ កម្មវិធីBlueJeans**

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តម តាមវីដេអូខនហ្វឺរេន នាពេលនេះ!

ឆ្លងកាត់នូវការចំណាយពេលដ៏មានតម្លៃពេញមួយព្រឹក កិច្ចប្រជុំពេញអង្គរបស់យើងបានធ្វើបទបង្ហាញ រួមជាមួយនឹងការពិភាក្សា និងផ្តល់យោបល់យ៉ាងផុសផុល ដែលនាំឱ្យយើងទទួលបាននូវលទ្ធផលគួរជាទីមោទនៈ ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

ទោះបីជាយើងធ្វើការពិភាក្សាតាមវីដេអូខនហ្វឺរេនក៏ពិតមែន តែដោយសារតែមានការចូលរួមយ៉ាងសកម្មពី ឯកឧត្តម លោកជំទាវ លោក លោកស្រី បានធ្វើឱ្យពេលវេលាដ៏មានតម្លៃរបស់យើងអាចទទួលបាននូវផ្លែផ្កា ដែលខ្ញុំសូមយកឱកាសនេះសម្តែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្របំផុតជូនសមាជិក សមាជិកា នៃអង្គពិធីទាំងមូល។

ខ្ញុំសូមអនុញ្ញាតឆ្លៀតឱកាសមុនបិទកិច្ចប្រជុំពេញអង្គរបស់យើង ផ្តល់ជូននូវចំណាប់អារម្មណ៍បូកសរុបលទ្ធផលជារួមដែលទទួលបានពីកិច្ចប្រជុំនេះ ដែលខ្ញុំសូមរំលឹកអង្គពិធីទាំងមូលអំពីកិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងរៀបចំដំណើរឆ្លងកាត់ពីអន្តរកាលឆ្ពោះទៅរកចីរភាពនៃការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ ក៏ដូចជាការធ្វើឱ្យសម្រេចគោលដៅ

របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្ដេជ្ញាបញ្ចប់ជំងឺអេដស៍ដែលជាការគំរាមកំហែងសុខភាពសាធារណៈនៅឆ្នាំ ២០២៥ ខាងមុខ ដែលរួមមានដូចតទៅ ៖

១) ជារួម យើងទាំងអស់គ្នាពិតជាបានខិតខំអនុវត្តផែនការសកម្មភាព រយៈពេល៦ខែចុងឆ្នាំ ២០២០ ទៅតាមក្រសួង ស្ថាប័នជាតិ អន្តរជាតិ សង្គមស៊ីវិល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាលទ្ធផលដែលយើងទទួលគឺអាចខុសៗគ្នាទៅតាមស្ថានភាពជាក់ស្ដែងរបស់ស្ថាប័ននីមួយៗ។

២) សូមលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី ខេត្ត ឱ្យបន្តជំរុញនិងចូលរួមសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសអាជ្ញាធរឃុំ សង្កាត់ ក្នុងការអនុវត្ត "សេចក្ដីជូនដំណឹងលេខ ២១៣ សជណ.សស" ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។

៣) ការកាត់បន្ថយថវិកាជាតិ ក្នុងបរិបទប្រឈមជាមួយនឹង Covit19 នេះ ជាបញ្ហាចម្បងមួយ រារាំងដល់ការអនុវត្តផែនការសកម្មភាពឱ្យបានពេញលេញ ដែលទាមទារការប្ដេជ្ញាចិត្តមុតមាំ ដើម្បីសម្រេចគោលដៅទៅតាមការគ្រោងទុក។

៤) ធ្វើការសិក្សាស្វែងយល់ និងពិនិត្យលទ្ធភាពក្នុងការពង្រីកការ គ្របដណ្ដប់ទៅកាន់ក្រុមគោលដៅថ្មី ជាពិសេសក្រុមប្រឈម ដែលមកទល់ពេលនេះមានការកើនឡើងគួរឱ្យព្រួយបារម្ភ ។

ជាមួយគ្នានេះផងដែរ ខ្ញុំសូមផ្ដល់ជូននូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១) អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវប្រមូលរាល់អនុសាសន៍ទាំងអស់ដែលបានអនុម័តជាគោលការណ៍នៅក្នុងកិច្ចប្រជុំនេះ ដើម្បីយកទៅរៀបចំ និងកែលម្អសម្រាប់ដាក់ចេញនូវគម្រោងផែនការសកម្មភាពក្នុងឆ្នាំខាងមុខ។

២) ជំរុញនិងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យនូវគំនិតផ្ដួចផ្ដើម ទីក្រុងរួមគ្នាពន្លឿនការឆ្លើយតបការរីករាលដាលជំងឺអេដស៍ (Fast-Track Cities Initiative) ដែលនឹងចាប់ដំណើរការ នៅក្នុងទីក្រុងភ្នំពេញ ខេត្តបាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ក្នុងពេលខាងមុខ។

៣) បន្តចូលរួមជា "**ចរន្តជាតិមួយ**" ក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

៤) បន្តជំរុញ និងលើកទឹកចិត្តក្រសួង ស្ថាប័នដែលពុំទាន់បានទទួលថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យលើកសំណើថវិកាឆ្នាំ២០២២ក្នុងកញ្ចប់នៃផែនការថវិការបស់ក្រសួងស្ថាប័នសាមីឱ្យបានព្រមៗគ្នា។

៥) បន្ត ពង្រឹង និងជំរុញលើកទឹកចិត្តគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន និង រាជធានី ខេត្ត ក្នុងការផ្តល់របាយការណ៍ឱ្យបានទៀងទាត់មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីពង្រឹងការអនុវត្តគោលការណ៍បីមួយ ៖ ស្ថាប័នដឹកនាំសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រតែមួយ និងប្រព័ន្ធតាមដានត្រួតពិនិត្យតែមួយ។

៦) ជំរុញ និងប្រើប្រាស់គ្រប់យន្តការទាំងអស់ ដើម្បីធ្វើឱ្យសម្រេចបានជោគជ័យក្នុងការអនុវត្តសកម្មភាពដាក់បញ្ចូល ការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ ក្រុង ស្រុក ( សូមបញ្ជាក់ថាមកទល់ពេលនេះ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បាននិងកំពុងធ្វើការបញ្ចូល ការងារឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ នេះ ចូលទៅគ្រប់ ស្រុក ឃុំ ក្នុងខេត្ត កំពង់ស្ពឺ ដែលមកទល់ពេលនេះ គ្រប់ ឃុំ សង្កាត់ទាំងអស់បានទទួលការបណ្តុះបណ្តាលផ្នែកបច្ចេកទេសបានរួចរាល់ហើយ ) ។

៧) បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីទទួលបានជំនួយទាំងសម្ភារ ថវិកា និងបច្ចេកទេស សម្រាប់បន្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាទៅមុខទៀត រហូតសម្រេចបានជោគជ័យក្នុងការលុបបំបាត់ជំងឺអេដស៍ ជាពិសេសគ្រប់គ្រងឱ្យបាននូវក្រុមប្រឈម ដែលនៅតែជាក្តីកង្វល់ដ៏ស្រួចស្រាវ ដែលតម្រូវឱ្យមានកម្មវិធីឆ្លើយតបប្រកបដោយប្រសិទ្ធភាពខ្ពស់ ដូចដែលយើងបានធ្វើចំពោះក្រុមនារីបម្រើសេវាកម្សាន្តសប្បាយនៅតាមគ្រឹះស្ថាននានាផងដែរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី!***

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំពេញអង្គដ៏មានសារៈសំខាន់នាពេលនេះ។ តាមរយៈការចូលរួមយ៉ាងសកម្ម ផ្តល់នូវគំនិតល្អៗ រួមជាមួយនឹងមតិដ៏ល្អ និងមានតម្លៃ នាំឱ្យយើងអាចយកទៅប្រើប្រាស់ក្នុងការកែលម្អការអនុវត្តការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរផងដែរចំពោះ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានខិតខំរៀបចំកិច្ចប្រជុំពេញអង្គនេះឱ្យប្រព្រឹត្តទៅបានដោយរលូន និងសម្រេចបាននូវផ្លែផ្កាគួរជាទីមោទនៈនាពេលនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់នូវពុទ្ធពរទាំងឡាយទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ និងជៀសផុតពីជំងឺកូវីដ-១៩ បានគ្រប់ៗគ្នា និងសូមប្រកាសបិទ **"កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ឆ្នាំ២០២០"** ចាប់ពីពេលនេះតទៅ!

***សូមអរគុណ!***